ទំនុកដំកើង៧៦-៧៨

# ជំពូក ៧៦

***ចំណងជើង*** *បទទំនាយពីព្រះមែស៊ីឡើងគ្រងរាជ្យ*

ពេលសិក្សាគម្ពីរទំនុកដំកើងពីជំពូក៧៦-៧៨ ខ្ញុំសូមលោកអ្នកមេត្តាបើកព្រះគម្ពីរនៅពីមុខលោកអ្នក។ សេចក្តីដែលសរសេរទាំងអម្បាលមាណនេះ ជាផ្នែកនៃអត្ថបទដែលព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ បណ្តាលអោយពួកហោរារបស់ទ្រង់កត់ទុករៀងមក។ ជំពូកនីមួយៗ សរសេររៀបរយមានសណ្តាប់ធ្នាប់ជាទីបំផុត។ ជំពូក៧៦ រៀបរាប់ពីហេតុការណ៍ ព្រះអម្ចាស់យេស៊ូវយាងមកបង្ក្រាបកងទ័ពកាចសាហាវគ្រប់គ្រងសកលលោកនៅគ្រាមហាទុក្ខ រួចហើយតាំងរាជ្យរបស់ទ្រង់នៅលើផែនដីយើងនេះ។ ព្រះអង្គគ្រប់គ្រងរាជ្យរបស់ទ្រង់ជាមហាក្សត្រ និងជាសម្តេចសង្ឃដ៏ខ្ពស់បំផុតមានលំដាប់ថ្នាក់ដូចសង្ឃម៉ិលគីស្សាដែក។ នៅក្នុងរាជ្យព្រះអម្ចាស់យេស៊ូវ មនុស្សគ្រប់ជាតិ គ្រប់សាសន៍ ចុះចូលចំពោះទ្រង់។ ពេលនោះឥតមានជាតិសាសន៍ណាងើបបះបោរទាស់នឹងព្រះអង្គទៀតឡើយ។

**¹នៅស្រុកយូដាគេស្គាល់ព្រះហើយ ព្រះនាមទ្រង់ក៏ធំ នៅក្នុងសាសន៍អ៊ីស្រាអែល ²រោងឧបោសថរបស់ទ្រង់នៅក្រុងសាឡិម ហើយទីលំនៅទ្រង់នៅភ្នំស៊ីយ៉ូន (ទំនុកដំកើង៧៦:១-២)។**

ទីក្រុងសាឡិម ជាឈ្មោះទីក្រុងមុនពេលហ្លួងដាវីឌប្តូរទៅជាឈ្មោះទីក្រុងយេរូសាឡិមដូចសព្វថ្ងៃ។ សាឡិមមានន័យថា សន្តិភាព។ នៅក្នុងខខាងលើ យើងឃើញរៀបរាប់ឈ្មោះភូមិស្រុកដូចជាយូដា អ៊ីស្រាអែល សាឡិម និងស៊ីយ៉ូន។ ភូមិស្រុកទាំងអស់នោះស្ថិតនៅមជ្ឈិមបូព៌ា។ ដូច្នេះ តាមការបកស្រាយអត្ថបទខាងលើសរសេរឡើងសម្រាប់ពលរដ្ឋរស់នៅមជ្ឈិមបូព៌ា។ ប៉ុន្តែ តាមការអនុវត្តន៍វិញ បទគម្ពីរខាងលើមានសារៈប្រយោជន៍សម្រាប់មនុស្សគ្រប់ជាតិសាសន៍។

**នៅទីនោះ ទ្រង់បានបំបាក់ព្រួញ ធ្នូ ខែល នឹងដាវ ហើយអស់ទាំងគ្រឿងចំបាំងបង់ -បង្អង់ (ទំនុកដំកើង ៧៦:៣)។**

"នៅទីនោះ" ជាទីដែលគម្ពីរអេសាយ២:៤ចែងថា "ទ្រង់នឹងវិនិច្ឆ័យរវាងអស់ទាំងនគរ ហើយនឹងសំរេចរឿងដល់សាសន៍ជាច្រើន នោះគេនឹងយកដាវរបស់ខ្លួនដំធ្វើជាផាលនង្គ័ល ហើយលំពែងគេធ្វើជាដង្កាវវិញ នគរ១នឹងមិនលើកដាវទាស់នឹងនគរ១ទៀតឡើយ ក៏មិនហាត់រៀនធ្វើសឹកសង្គ្រាមទៀតដែរ"។

ពេលព្រះអម្ចាស់យេស៊ូវយាងមកតាំងរាជ្យរបស់ទ្រង់នៅលើផែនដី រាជ្យរបស់ទ្រង់មានសន្តិភាព មានភាពយុត្តិធម៌ និងសមធម៌យ៉ាងបរិបូរ។ រាជ្យនេះ ត្រូវកើតមានឡើងបន្ទាប់ពីមនុស្សមួយពួកបែរមកទទួលជឿព្រះអង្គយេស៊ូវជាអង្គសង្គ្រោះ ហើយមនុស្សមួយពួកទៀត ត្រូវព្រះអម្ចាស់យេស៊ូវជំនុំជំរះអំពើដែលគេបានប្រព្រឹត្តកាលគេរស់នៅលើផែនដីនេះ។

**ទ្រង់រុងរឿងឧត្តម ហើយមានលំអប្រសើរ ជាងភ្នំរំពាទាំងប៉ុន្មាន (ទំនុកដំកើង៧៦:៤)។**

"ភ្នំរំពា" គឺទីក្រុងយេរូសាឡិម។ ទីក្រុងយេរូសាឡិមជារំពារបស់មនុស្សគ្រប់ជាតិសាសន៍។ មកទល់ពេលបច្ចុប្បន្ននេះ ទីក្រុងយេរូសាឡិមត្រូវសត្រូវចូលមកធ្វើការបំផ្លិចបំផ្លាញអស់ចំនួន២៧ដងរួចមកហើយ។ បច្ចុប្បន្ន ទីក្រុងយេរូសាឡិមក៏នៅតែជារំពារបស់ជាតិសាសន៍ជាច្រើន។

ប៉ុន្តែ ព្រះជាម្ចាសមិនបណ្តោយអោយជនមានអំនួតណាមួយអាចគ្រប់គ្រងទីក្រុងយេរូសាឡិមជាស្ថាពរបានជាដាច់ខាត។

**ពួកអ្នកដែលមានចិត្តក្លាហាន គេបានត្រឡប់ជារំពាវិញ គេបានដេកអស់ពេលដេករបស់គេហើយ ក្នុងពួកអ្នកខ្លាំងពូកែទាំងប៉ុន្មាន**

**គ្មានអ្នកណាមួយអាចលើកដៃឡើងបានឡើយ (ទំនុកដំកើង ៧៦:៥)។**

“គេបានដេកអស់ពេលដេករបស់គេហើយ” មានន័យថា គេដេកមិនចេះផ្អែត។ មនុស្សលោកចូលចិត្តដេកក្នុងអំពើបាបរបស់ខ្លួន។ គេមិនព្រមភ្ញាក់ដឹងខ្លួនចេញពីអំពើបាបមកទទួលព្រះអង្គសង្គ្រោះទេ។ គម្ពីរ១យ៉ូហាន៥:១៩ ពណ៌នាថា មនុស្សក្នុងលោកនាំគ្នាដេកលើអង្រឹងមាស មានសាតាំងជាអ្នកច្រៀងបំពេរ។ បើលោកអ្នកផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ អោយមនុស្សលោកបានរួចពីបាប សាតាំងគម្រាមកំហែងសម្លុតលោកអ្នក កុំអោយនិយាយព្រះបន្ទូលឮពេក ក្រែងមនុស្សមានបាបភ្ញាក់ពីដេក។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ យើងត្រូវផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីអោយពួកកូនក្មេងបានឮថា សេចក្តីជំនុំជំរះរបស់ព្រះជាម្ចាស់ជិតមកដល់ហើយ ឯសេចក្តីសង្គ្រោះក្នុងព្រះអម្ចាស់យេស៊ូវក៏នៅជិតបង្កើយដែរ។

“គ្មានអ្នកណាមួយអាចលើកដៃឡើងបានឡើយ”។ ព្រះជាម្ចាស់ចង់មានបន្ទូលទៅកាន់មនុស្សចូលចិត្តដេកថា “ងើបឡើង ក្រែងលោដល់ពេលងើប ព្រះគ្រីស្ទយាងមកដល់ជាស្រេច”។ ហេតុការណ៍នោះមានបរិយាយក្នុងគម្ពីរពួកចៅហ្វាយ។ លោកគីឌាននាំកងឈ្លបមួយក្រុមទៅវាយបំបែកបន្ទាយពួកសាសន៍ម៉ាឌាន ដែលឈ្លានពានស្រុកភូមិរបស់លោក។ នៅពេលសាសន៍ម៉ាឌានភ្ញាក់ដឹងខ្លួន ទ័ពរបស់លោកគីឌានបានវាយលុកដល់បន្ទាយខ្លួនរួចជាស្រេច។ គម្ពីរពួកចៅហ្វាយ៧:២១សម្តែងពីហេតុការណ៍នោះ។

**ឱព្រះនៃយ៉ាកុបអើយ កាលណាទ្រង់បន្ទោស នោះទាំងរទេះចំបាំង នឹងសេះផង ក៏ត្រូវលក់សិបទាំងអស់គ្នា (ទំនុកដំកើង ៧៦:៦)។**

នៅពេលព្រះអម្ចាស់ព្រះយេស៊ូវយាងមកតាំងរាជ្យទ្រង់ ទ្រង់ធ្វើអោយសេះ និងអ្នកបររទេះចំបាំងទន់ភ្នែក រកងើបពីដំណេករបស់ខ្លួនមិនកើត។ ពេលគេបើកភ្នែកដឹងខ្លួន គេឃើញសិរីល្អរបស់ព្រះអម្ចាស់យេស៊ូវយាងមកដល់ជាស្រេច។ គម្ពីរអេសាយ ៦០:១ សម្តែងពីថ្ងៃនោះថា "ចូរក្រោកឡើង ហើយភ្លឺមកចុះ ដ្បិតពន្លឺរបស់ឯងបានមកដល់ហើយ សិរីល្អនៃព្រះយេហូវ៉ាក៏បានរះឡើងដល់ឯងដែរ"។ មួយទៀត គម្ពីរអេសាយ៤:៥សម្តែងបន្ថែមថា "ព្រះយេហូវ៉ា ទ្រង់នឹងបង្កើតឱ្យមានពពកនឹងផ្សែងនៅវេលាថ្ងៃ ហើយភ្លើងដ៏ឆេះបំភ្លឺនៅវេលាយប់ ពីលើទីលំនៅទាំងមូលនៅភ្នំស៊ីយ៉ូន ហើយពីលើទីប្រជុំទាំងប៉ុន្មានរបស់គេ ដ្បិតគ្រប់ទាំងទីគួរគោរព នឹងមានគំរបគ្របបាំងទាំងអស់"។ សិរីល្អរបស់ព្រះជាម្ចាស់ដែលត្រូវយាងមកក្នុងពេលនោះ គឺអង្គព្រះយេស៊ូវគ្រីស្ទផ្ទាល់តែម្តង។

បន្ទាប់ពីពេលនោះមក ថ្ងៃនៃសេចក្តីសងសឹករបស់ព្រះបានឈានមកដល់។

**"គឺទ្រង់ ទ្រង់តែ១ប៉ុណ្ណោះ ដែលគួរស្ញែងខ្លាច កាលណាទ្រង់មានសេចក្តីខ្ញាល់ នោះតើអ្នកណាអាចនឹងឈរនៅចំពោះទ្រង់បាន**

**៨ ទ្រង់បានឱ្យឮពាក្យកាត់ទោសពីលើស្ថានសួគ៌មក ផែនដីក៏ភ័យ
ខ្លាច ហើយស្ងៀមឈឹងនៅ ៩ គឺក្នុងកាលដែលព្រះទ្រង់ឈរឡើង
ដើម្បីជំនុំជំរះប្រយោជន៍នឹងជួយសង្គ្រោះដល់ពួកមនុស្សរាបសា
នៅផែនដី -បង្អង់ (ទំនុកដំកើង៧៦:៧-៩)។**

គម្ពីរវិវរណៈជំពូក៦:១៧បំភ្លឺបន្ថែមថា "ដ្បិតថ្ងៃធំនៃសេចក្ដីក្រោធរបស់ទ្រង់បានមកដល់ហើយ តើអ្នកណាអាចនឹងឈរនៅបាន"។ ពេលព្រះអម្ចាស់យេស៊ូវយាងត្រឡប់មកផែនដីវិញ អំណាចគ្រប់គ្រងគ្រប់បែបយ៉ាងនៅលើលោកនេះ ត្រូវស្ថិតនៅក្រោមព្រះបាទារបស់ទ្រង់វិញ។

**ពិតប្រាកដជាសេចក្ដីឃោរឃៅរបស់មនុស្ស នឹងសរសើរទ្រង់ ឯសំណល់សេចក្ដីឃោរឃៅ នោះទ្រង់នឹងរួបរឹតទុកវិញ (ទំនុកដំកើង៧៦:១០)។**

ព្រះជាម្ចាស់អនុញ្ញាតអោយមនុស្សលោក ប្រព្រឹត្តត្រឹមព្រំដែនដែលទ្រង់កំណត់។ ចំណែកក្នុងគ្រាមហាទុក្ខវិញ ព្រះជាម្ចាស់ហាក់បណ្ដោយអោយមនុស្សលោកប្រព្រឹត្តលើសពីព្រំដែនបន្តិច។ រីឯសព្វថ្ងៃនេះវិញ មនុស្សលោកមិនអាចប្រព្រឹត្តអាក្រក់លើសពីព្រំដែលដែលព្រះជាម្ចាស់កំណត់អោយ។ ព្រះវិញ្ញាណរបស់ព្រះមាននាទីកំណត់

ព្រំដែនអោយមនុស្សលោកប្រព្រឹត្ត។ ទោះបីមនុស្សប្រើអំពើឃោរឃៅដើម្បីសម្រេចទិសដៅរបស់ខ្លួន ជួនកាលព្រះជាម្ចាស់បំផ្លាស់បំប្រែសេចក្តីឃោរឃៅទាំងនោះ ទៅជាសេចក្តីសរសើរដល់ទ្រង់ក៏សឹងមានដែរ។

> **ចូរបន់ព្រះយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ហើយលាបំណន់នោះចុះ ចូរឱ្យអស់អ្នកដែលនៅជុំវិញទ្រង់ យកដង្វាយមកថ្វាយដល់ព្រះដ៏គួរស្ញែងខ្លាច (ទំនុកដំកើង ៧៦:១១)។**

បច្ចុប្បន្ន សាតាំងធ្វើការទាស់នឹងព្រះជាម្ចាស់ និងព្រះគ្រីស្ទដែលព្រះអង្គតែងតាំងអោយមកសង្គ្រោះមនុស្សលោកចេញពីអំពើបាប។ ប៉ុន្តែ សាតាំងអាចធ្វើអ្វីនៅលើលោកនេះ ក្នុងព្រំដែនព្រះជាម្ចាស់កំណត់អោយវាតែប៉ុណ្ណោះ។ គម្ពីរទំនុកដំកើង ១១០:៣ សម្តែងថា "រាស្ត្ររបស់ឯងគេថ្វាយខ្លួនស្ម័គ្រពីចិត្ត នៅថ្ងៃដែលឯងដំរៀបក្បួនទ័ពដ៏ប្រដាប់ដោយគ្រឿងបរិសុទ្ធ ពួកកំឡោះរបស់ឯង នឹងបានដូចជាទឹកសន្សើមដែលចេញពីផ្ទៃនៃបច្ចូសកាលមក"។ ព្រះជាម្ចាស់កំណត់ព្រំដែនអោយសាតាំង ដើម្បីអោយរាស្ត្រអ៊ីស្រាអែលជារាស្ត្ររបស់ព្រះអង្គ អាចលាងសម្បថដែលខ្លួនបានស្បថដល់ព្រះជាម្ចាស់។ ចំណែកសាសន៍ដទៃ ក៏អាចមានលទ្ធភាពចុះចូលចំពោះព្រះជាម្ចាស់ជាអង្គសង្គ្រោះ។ គម្ពីរទំនុកដំកើងជំពូក៧២:១០-១១ សម្តែងថា "ពួកក្សត្រនៃស្រុកតើស៊ីស នឹងកោះទាំងប៉ុន្មាន នឹងថ្វាយសួយអាករ ពួកក្សត្រនៃស្រុកសេបា នឹងស្រុក

សាបា នឹងថ្វាយគ្រឿងបណ្ណាការដែរ អើ ពួកក្សត្រទាំងអស់ នឹងផ្តួលខ្លួនក្រាបចុះនៅចំពោះទ្រង់ ហើយអស់ទាំងនគរនឹងចំណុះទ្រង់ដែរ"។

ថ្ងៃដែលព្រះអម្ចាស់យាងមកជាថ្ងៃពេញដោយសិរីល្អ។ បទគម្ពីរជំពូក៧៦ សម្តែងអោយយើងឃើញពីការដ៏ល្អនៅគ្រាអនាគត។

# ជំពូក ៧៧

***ឆាវឆនា*** *ភាពអល់អែកចំពោះសេចក្តីមេត្តា និងសេចក្តីល្អរបស់ព្រះជាម្ចាស់។*

ជំពូក៧៧ជាទំនុកសម្រាប់ប្រៀនប្រដៅ។ រាស្ត្ររបស់ព្រះជាម្ចាស់មានភាពយល់មិនច្បាស់នូវសេចក្តីមេត្តាករុណា និងសេចក្តីសប្បុរសរបស់ទ្រង់។ ហេតុនេះហើយបានជាព្រះវិញ្ញាណបរិសុទ្ធ បណ្តាលអោយពួកហោរាបានកត់ត្រាទុកនូវសេចក្តីក្នុងជំពូកនេះរំឮករាស្ត្រទ្រង់ និងមនុស្សលោក អោយយល់ពីសេចក្តីសប្បុរស និងសេចក្តីមេត្តាករុណារបស់ព្រះអង្គ។ យើងអាចស្គាល់សេចក្តីមេត្តាករុណា និងសេចក្តីសប្បុរសរបស់ទ្រង់ដោយជំនឿ។ ជំនឿមានឧបសគ្គ តែមានផ្លូវដោះស្រាយជានិច្ច។ ដំណោះស្រាយនៃឧបសគ្គខាងជំនឿរកឃើញនៅក្នុងដំណាក់ព្រះជាម្ចាស់។ ព្រះជាម្ចាស់មិនដែលភ្លេចពាក្យសន្យា ទ្រង់បានធ្វើចំពោះមនុស្សលោកឡើយ។

**១ ខ្ញុំបន្លឺសំឡេង អំពាវនាវដល់ព្រះ ខ្ញុំបន្លឺសំឡេងឡើងដល់ព្រះ**
**ហើយទ្រង់ក៏ស្តាប់ខ្ញុំ ២ នៅថ្ងៃដែលខ្ញុំមានសេចក្តីវេទនា នោះខ្ញុំ**

**បានស្វែងរកព្រះអម្ចាស់ នៅពេលយប់ នោះខ្ញុំបានប្រទូលដៃឡើង ឥតឈប់ឈរ ព្រលឹងខ្ញុំមិនព្រមក្សាន្តទុក្ខទេ (ទំនុកដំកើង ៧៧:១-២)។**

តើគ្រាណាមួយ ជាគ្រាល្អសម្រាប់អោយមនុស្សលោកស្វែងរកព្រះភក្ត្រព្រះជាម្ចាស់? គឺគ្រាមនុស្សលោកជួបទុក្ខលំបាក។ គ្រីស្ទបរិស័ទម្នាក់ជាអ្នកជំនួញ។ ពេលគាត់រកស៊ីកាក់កប គាត់មិនដែលគិតពីព្រះជាម្ចាស់ថាជាអ្នកផ្គត់ផ្គង់ដល់លោកឡើយ។ ពេលមួយរបររកស៊ីរបស់គាត់ត្រូវរលាយដូចអំបិលត្រូវទឹក។ លោកចំណាយពេលស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលយើងបានផ្សព្វផ្សាយតាមវិទ្យុ។ លោកជម្រាបយើងថា ក្នុងគ្រាឆ្លងទុក្ខលំបាក លោកសម្រេចចិត្តជឿដល់ព្រះអម្ចាស់យេស៊ូវ ជាអង្គសង្គ្រោះរបស់លោកផ្ទាល់។ នៅក្នុងពេលមានទុក្ខលំបាក យើងអាចអំពាវនាវហៅរកព្រះជាម្ចាស់អោយជួយយើង។

"ហើយទ្រង់ក៏ស្តាប់ខ្ញុំ" ព្រះជាម្ចាស់ពិតជាស្តាប់ដល់លោកអ្នក ពេលលោកអ្នកអំពាវនាវហៅរកទ្រង់។ បទពិសោធន៍នេះ ជាភ័ស្តុតាងបញ្ជាក់ថា នៅលើលោកនេះមានព្រះជាម្ចាស់គង់នៅ។

"ព្រលឹងខ្ញុំមិនព្រមក្សាន្តទុក្ខទេ"។ សេចក្តីទុក្ខប្រភេទនេះ មានកប់យ៉ាងជ្រៅនៅក្នុងព្រលឹងរបស់លោកអេសាភ។ ប្រឈមមុខនឹងស្ថានភាពបែបនេះ លោកមានប្រសាសន៍ក្នុងខខាងក្រោមនេះថា:

**ទូលបង្គំនឹកឃើញទំនុកដែលធ្លាប់ច្រៀងនៅពេលយប់ នោះទូលបង្គំបានត្រិះរិះក្នុងចិត្ត ហើយវិញ្ញាណទូលបង្គំ ក៏ស្វែងរកសេចក្ដីចំឡើយដែរ (ទំនុកដំកើង៧៧:៦)។**

នៅពេលយប់ យើងអាចច្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់ក៏បាន។ តែមិនត្រូវច្រៀងឡូឡារកអ្នកជិតខាងដេកមិនបាននោះទេ។ បញ្ហាដែលលោកអ្នកគិតឃើញនៅពេលយប់ ហាក់ដូចជាមានទំហំធំជាងបញ្ហាពិតប្រាកដ ដែលកើតឡើងនៅថ្ងៃស្អែក។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ពេលយប់ព្រះជាម្ចាស់ប្រទានអោយមានបទចម្រៀងនៅក្នុងដួងចិត្តរបស់យើង។

លោកអេសាភលើកជាសំណួរសួរឡើង ពីព្រោះលោកឃើញមានភាពអល់អែក រាស្ត្រអ៊ីស្រាអែលមានចំពោះសេចក្ដីមេត្តាករុណា និងសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់។

**៧ តើព្រះអម្ចាស់ទ្រង់នឹងបោះបង់ចោលជាដរាបឬ តើទ្រង់មិនព្រម
ប្រោសប្រាណទៀតទេឬ ៨ តើសេចក្ដីសប្បុរសនៃទ្រង់អស់រលីងជា
ដរាបទៅឬ តើសេចក្ដីសន្យាទ្រង់អាក់ខានទៅជានិច្ចឬ ៩ តើព្រះ
ទ្រង់ភ្លេចប្រព្រឹត្តដោយករុណារបស់ទ្រង់ហើយឬ តើទ្រង់បានបិទ**

**បាំងសេចក្តីអាណិតមេត្តារបស់ទ្រង់ទុក ដោយសេចក្តីខ្ញាល់ដែរឬអី (ទំនុកដំកើង៧៧:៧-៩)។**

តាមពិតជនដែលគ្មានព្រះជាម្ចាស់ទេ ត្រូវសួរសំណួរដូចខាងលើ។ ប៉ុន្តែ បើតាមការជាក់ស្តែងវិញ ខ្ញុំផ្ទាល់ជាអ្នកជឿព្រះអម្ចាស់យេស៊ូវយ៉ាងមុតមាំ មានសំណួរបែបនេះដែរ។ លោកអ្នកប្រហែលជាមានសំណួរដូច្នេះដែរទេដឹង? អ្នកជឿដល់ព្រះអម្ចាស់យេស៊ូវច្រើនគ្នាណាស់ ប្រព្រឹត្តកិរិយាដូចអ្នកមិនជឿថាមានព្រះ។ សព្វថ្ងៃ លោកអ្នកហើយនិងរូបខ្ញុំរស់ហាក់ដូចជាគិតថា ព្រះជាម្ចាស់មិនគង់នៅលើផែនដីនេះទេ។ យើងអធិស្ឋានមែន តែក្នុងសេចក្តីអធិស្ឋាន យើងហាក់ដូចជាមិនជឿថា ព្រះជាម្ចាស់ឆ្លើយតបនឹងសេចក្តីអធិស្ឋានយើងសោះ។ ជួនកាលយើងយល់ថា ព្រះជាម្ចាស់បោះយើងចេញពីនាវាជីវិត អោយយើងហែលក្នុងមហាសាគរតែម្នាក់ឯង។ មួយថ្ងៃៗ យើងរស់នៅហាក់ដូចជាគិតថា ព្រះជាម្ចាស់ឈប់ផ្តល់ព្រះគុណមកដល់យើង។ លោកអ្នកបងប្អូនស្ងួនភ្ងាក្នុងអង្គព្រះគ្រីស្ទអើយ! ព្រះជាម្ចាស់មានព្រះហឫទ័យសប្បុរសចំពោះយើងណាស់។ ព្រះអង្គចង់បង្ហាញសេចក្តីមេត្តាករុណារបស់ទ្រង់ ចំពោះលោកអ្នកហើយនិងរូបខ្ញុំផ្ទាល់។ ទោះបីយើងបានធ្វើអ្វីទាស់នឹងព្រះអង្គក៏ដោយ ព្រះអង្គចង់សម្តែងសេចក្តីល្អរបស់ទ្រង់ចំពោះយើងគ្រប់គ្នា។

**ឱព្រះអង្គអើយ ផ្លូវទ្រង់ជាផ្លូវបរិសុទ្ធ តើមានព្រះឯណាដែលធំដូច**

ជាទ្រង់ (ទំនុកដំកើង៧៧:១៣)។

យើងកំពុងសិក្សាកណ្ឌព្រះគម្ពីរទំនុកដំកើង មហាវគ្គលេវីវិន័យ។ ពាក្យគន្លឹះសម្រាប់មហាវគ្គលេវីវិន័យ គឺបរិសុទ្ធ និងយញ្ញបូជា។ នៅក្នុងរោងឧបោសថមានទីបរិសុទ្ធ និងទីបរិសុទ្ធបំផុត។ ពេលយើងចូលទៅក្នុងដំណាក់របស់ព្រះអង្គ ទ្រង់ប្រទានសេចក្តីបរិសុទ្ធរបស់ទ្រង់មកដល់យើង។ គម្ពីរហេព្រើរ១០:២៥សម្តែងថា "ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឱ្យកំឡាចិត្តគ្នាវិញ ឱ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថាថ្ងៃនោះជិតមកដល់ហើយ"។ ក្នុងចំណោមរាស្ត្ររបស់ព្រះជាម្ចាស់ យើងតែងជួបជុំគ្នាដើម្បីថ្វាយបង្គំព្រះអង្គ។ បន្ទាប់ពីលោកអ្នកបានជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទហើយ ព្រះអង្គមិនចង់អោយលោកអ្នកផ្តាច់ខ្លួននៅតែឯង សប្បាយរីករាយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឥតគិតគូរដល់រាស្ត្ររបស់ព្រះអង្គណាផ្សេងទៀតនោះឡើយ។ ភារៈរបស់យើងត្រូវចែកចាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដល់មនុស្សផងទាំងពួងមានដល់អ្នកជឿជាដើម។ ធ្វើយ៉ាងដូច្នោះ ញ៉ាំងយើងមានការលូតលាស់ក្នុងជំនឿព្រមគ្នាជាមួយនឹងបងប្អូនឯទៀតៗ ដែលគេជឿព្រះអង្គដូចយើងដែរ។ ខ្ញុំផ្ទាល់មិនយល់នឹងកិរិយាគ្រីស្ទបរិស័ទខ្លះរាប់ខ្លួនឯងថា ជាអ្នកមានពេញទៅដោយព្រលឹងវិញ្ញាណជាងគ្រីស្ទបរិស័ទឯទៀត។ ព្រះជាម្ចាស់មិនដែលអោយកូនរបស់ព្រះអង្គណាមួយ លូតលាស់ជាងកូនព្រះអង្គមួយទៀតទេ។ យើងមានការលូតលាស់ស្មើៗគ្នា ទទួលព្រះពរប្រហាក់ប្រហែលគ្នា និងទទួលសេក្តីសុខសាន្តពីព្រះជាម្ចាស់ដូចគ្នាសុទ្ធសាធ។ នៅក្នុងគ្រួសារ

របស់ព្រះជាម្ចាស់យើងត្រូវចែករំលែកព្រះបន្ទូលព្រះអង្គ និងព្រះពររបស់ទ្រង់ដល់គ្នាទៅវិញទៅមក។ ការចូលមកដំណាក់របស់ព្រះជាម្ចាស់ ជាការចែករំលែកសេចក្ដីសប្បាយនិងទុក្ខលំបាករួមគ្នា។ បើលោកអ្នករស់នៅដាច់តែម្នាក់ឯង លោកអ្នកគ្មានចម្លើយសម្រាប់ជីវិតទេ។ បើលោកអ្នកចូលរួមប្រកបជាមួយនឹងរាស្ត្ររបស់ទ្រង់ លោកអ្នកស្វែងរកចម្លើយ បានយ៉ាងច្រើនចំពោះបញ្ហានៃជីវិតនេះ។

ខាងក្រោម ជាសេចក្ដីដែលលោកអេសាភសម្ដែងពីទិដ្ឋភាពកើតឡើងនៅក្នុងសមុទ្រ។

> **១៦ឱព្រះអង្គអើយ ទឹកទាំងប៉ុន្មានបានឃើញទ្រង់ គឺទឹកទាំងប៉ុន្មាន
> បានឃើញទ្រង់ ហើយមានសេចក្តីភិតភ័យ អស់ទាំងទីជំរៅក៏ញ័រ
> ដែរ ១៧អស់ទាំងពពកបានចាក់ទឹកចេញ ផ្ទៃមេឃក៏បញ្ចេញសូរ
> រំពង ហើយព្រួញរបស់ទ្រង់បានហើរទៅគ្រប់អន្លើដែរ ១៨សូរ
> សៀងនៃផ្គររបស់ទ្រង់ក៏នៅក្នុងខ្យល់កួច ផ្លេកបន្ទោរបានបំភ្លឺ
> លោកីយ ឯផែនដីក៏ញ័ររកក្រើក ១៩ផ្លូវដែលទ្រង់យាង នោះនៅក្នុង
> សមុទ្រ ហើយផ្លូវច្រករបស់ទ្រង់ ក៏នៅទីមានទឹកច្រើនឥតមាន
> អ្នកណាឃើញដានព្រះបាទទ្រង់ឡើយ (ទំនុកដំកើង៧៧:១៦-
> ១៩)។**

បទខាងលើ សម្តែងពីព្រះហស្តរបស់ព្រះជាម្ចាស់ ពេលទ្រង់ដឹកនាំសាសន៍អ៊ីស្រាអែលឆ្លងកាត់សមុទ្រក្រហម។

**ទ្រង់បាននាំរាស្ត្រទ្រង់ ដូចជាហ្វូងចៀម គឺដោយដៃរបស់ម៉ូសេ និងអើរ៉ុន (ទំនុកដំកើង៧៧:២០)។**

ខខាងលើ មានសេចក្តីពិតសម្រាប់យើងយកមកអនុវត្ត។ ព្រះជាម្ចាស់មានចេស្តាគ្រប់គ្រាន់ ដើម្បីរំដោះរាស្ត្រទ្រង់អោយរួចពីសម្ពាធនៃអ្នកមិនជឿដល់ព្រះជាម្ចាស់។ មិនតែប៉ុណ្ណោះ ព្រះអង្គមានចេស្តាអាចរំដោះយើងអោយរួចពីសង្គមមនុស្សដែលមិនចេះគោរពច្បាប់ និងសង្គមមានសីលធម៌ធ្លាក់ចុះយ៉ាងដុនដាប។ ព្រះអម្ចាស់យេស៊ូវជាអ្នកគង្វាលដ៏ល្អជាទីបំផុត ទ្រង់ឃ្វាលយើង ពេលយើងឆ្លងកាត់វាលកំដៅនៃទុក្ខលំបាក និងវាលកនៃការមិនជឿដល់ព្រះអង្គ។

# ជំពូក ៧៨

*ធាតុចនា ប្រវត្តិសាសន៍អ៊ីស្រាអែល*
*រាប់ចាប់ពីលោកម៉ូសេមកទល់នឹងព្រះបាទដាវីឌ*

ទំនុកដំកើងជំពូក៧៨ ក៏ជាសេចក្ដីបង្រៀនដែរ។ លោកអេសាភរំឭកដល់សាសន៍អ៊ីស្រាអែល ពីប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអែល ចាប់តាំងពីគ្រាដែលគេចាកចេញពីប្រទេសអេស៊ីព្ទ មកទល់នឹងគ្រាដែលព្រះបាទដាវីឌគ្រងរាជ្យ។ នៅក្នុងយុគសម័យនោះ យើងឃើញមានភាពបរាជ័យជាបន្តបន្ទាប់នៃរាស្ត្ររបស់ព្រះជាម្ចាស់ និងសេចក្ដីពោរពេញរបស់ព្រះអង្គ ក្នុងការផ្ដល់ជំនួយដល់រាស្ត្រទ្រង់។ គម្ពីរទំនុកដំកើងជំពូក៧៨ មានខ្លឹមសារខាងព្រលឹងវិញ្ញាណយ៉ាងជ្រាលជ្រៅ។ ព្រះជាម្ចាស់តែងឆ្លើយនឹងសេចក្ដីអំពាវនាវរបស់រាស្ត្រទ្រង់។

ព្រះជាម្ចាស់សព្វព្រះហឫទ័យអោយរាស្ត្រទ្រង់ស្ដាប់សម្លេង ដែលទ្រង់ត្រាស់ហៅដល់គេ។

**ឱសាសន៍របស់ខ្ញុំអើយ ចូរប្រុងត្រចៀកស្ដាប់សេចក្ដីបង្រៀនរបស់**

**ខ្ញុំ ហើយផ្ទៀងត្រចៀកស្តាប់អស់ទាំងពាក្យដែលចេញពីមាត់ខ្ញុំចុះ (ទំនុកដំកើង៧៨:១)។**

គម្ពីរទំនុកដំកើង៧៨ថែងសេចក្តីយ៉ាងវែង តែដោយសារពេលវេលាមានកម្រិត យើងគ្រាន់តែច្បិចយកចំណុចខ្លះៗមកពន្យល់តែប៉ុណ្ណោះ។

**៩ឯពួកកូនចៅអេប្រាអិមដែលមានគ្រឿងធ្នូ ហើយក៏ប្រសប់បាញ់ គេបានបែរខ្នងនៅថ្ងៃសឹកសង្គ្រាម ១០គេមិនបានកាន់តាមសេចក្តីសញ្ញារបស់ព្រះ ក៏មិនព្រមប្រព្រឹត្តតាមក្រឹត្យវិន័យទ្រង់សោះ (ទំនុកដំកើង៧៨:៩-១០)។**

គ្រួសារអេប្រាអិម មិនបានទៅច្បាំងជួយស្រោចស្រង់បងប្អូនខ្លួនទេ។ ព្រះជាម្ចាស់កត់ចំណាំទុកនូវកិរិយាខ្វះការសាមគ្គីជាមួយបងប្អូនឯទៀត។ កិរិយាខ្វចអាក្រក់នេះ ទាំងសាសន៍អ៊ីស្រាអែល ទាំងសាសន៍ដទៃ។ ព្រះជាម្ចាស់កត់ចំណាំឃើញថា ការខ្វះសាមគ្គីភាព មានទាំងក្នុងចំណោមសាសន៍អ៊ីស្រាអែល ក៏ដូចជាក្រុមជំនុំរបស់ព្រះអម្ចាស់យេស៊ូវ។ ប៉ុន្តែ ចំណែកព្រះជាម្ចាស់វិញ សេចក្តីស្មោះត្រង់របស់ទ្រង់ចំពោះរាស្ត្ររបស់ព្រះអង្គ មិនដែលប្តូរផ្លាស់មួយជំហានណាក៏គ្មានដែរ។

**[១៧] ទោះបើយ៉ាងនោះ គង់តែគេនៅតែធ្វើបាបនឹងទ្រង់ទៀត ជាការបះបោរនឹងព្រះដ៏ខ្ពស់បំផុតត្រង់ទីរហោស្ថាន [១៨] គេបានល្បងលព្រះនៅក្នុងចិត្តគេ ដោយសូមអាហារតាមគេប្រាថ្នា [១៩] អើ គេបាននិយាយទំនាស់នឹងព្រះ ដោយពាក្យថា តើព្រះទ្រង់អាចនឹងចាត់ចែងឱ្យមានអាហារបរិភោគនៅទីរហោស្ថាននេះបានឬ (ទំនុកដំកើង៧៨:១៧-១៩)។**

រាស្ត្ររបស់ព្រះជាម្ចាស់ ចូលចិត្តល្បងលទ្រង់ណាស់។ គេល្បងលទ្រង់ពីព្រោះគេមិនជឿលើសេចក្ដីសន្យារបស់ព្រះអង្គ។ ទាក់ទងនឹងដំណើរនេះ អ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ មានកិរិយាមិនខុសពីអ្នកដែលមិនជឿថាមានព្រះនៅលើលោកប៉ុន្មានទេ។

ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ សូមសង្កេតមើលពីសកម្មភាពដែលព្រះជាម្ចាស់ធ្វើចំពោះរាស្ត្រទ្រង់:

**គេបានបរិភោគនំរបស់ពួកទេវតាទាំងអស់គ្នា ទ្រង់បានផ្ញើអាហារមកគេឱ្យបានឆ្អែត (ទំនុកដំកើង៧៨:២៥)។**

"នំរបស់ពួកទេវតា" ត្រង់នេះគួរប្រែថា អាហារសម្រាប់ពួកខ្លាំងពូកែ។

ខគម្ពីរខាងលើសម្តែងពីមនុស្សគ្រប់ជាតិគ្រប់រូប សុទ្ធតែទទួលអាហារបានពីព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ។ ខ្លះបរិភោគអាហារយ៉ាងល្អប្រណីត ខ្លះបរិភោគអាហារធម្មតា គ្រប់គ្នាមានអាហារបរិភោគបានឆ្អែតឆ្អន់។ ប៉ុន្តែ កំពុងតែពោះគេបានឆ្អែត គេសួរដល់ព្រះជាម្ចាស់ គេរិះគន់ដល់ព្រះអង្គតាមអំពើចិត្តគេនឹកឃើញ។ កិរិយាខូចអាក្រក់នេះហើយ ជាកិរិយារបស់មនុស្សលោក។

> **៧០ ទ្រង់ក៏រើសដាវីឌ ជាអ្នកបំរើទ្រង់ ហើយនាំយកលោកចេញពី**
> **ក្រោលចៀមមក ៧១ គឺទ្រង់នាំយកលោកពីការឃ្វាលមេចៀមដែល**
> **មានកូន ដើម្បីឱ្យធ្វើជាអ្នកគង្វាលដល់ពួកយ៉ាកុប ជារាស្ត្រទ្រង់ គឺ**
> **ពួកអ៊ីស្រាអែលដែលជាមរដករបស់ទ្រង់វិញ ៧២ ដូច្នេះ លោកក៏ធ្វើ**
> **ជាអ្នកគង្វាលឃ្វាលគេដោយចិត្តទៀងត្រង់ ព្រមទាំងនាំផ្លូវគេ**
> **ដោយថ្វីដៃដ៏ជំនាញ (ទំនុកដំកើង៧៨:៧០-៧២)។**

ព្រះបាទដាវីឌ មានបុគ្គលិកលក្ខណៈដូចព្រះអម្ចាស់យេស៊ូវ ក្នុងករណីមានចិត្តទៀងត្រង់។ ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ចំពោះសាសន៍អ៊ីស្រាអែល។ ព្រះអង្គក៏មានព្រះហឫទ័យស្មោះត្រង់ចំពោះយើង ដែលរស់នៅក្នុងគ្រាបច្ចុប្បន្ននេះដែរ។

យើងស្លេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"